ផលធៀបៈ សិស្ស-គ្រូ, សិស្ស-ថ្នាក់, ថ្នាក់-បន្ទប់រៀនឆ្នាំសិក្សា ២០១៦-២០១៧

| បរិយាយ | សិស្ស-គ្រូ | សិស្ស-ថ្នាក់ | សិស្ស-បន្ទប់រៀន |
|---|---|---|---|
| អនុវិទ្យាល័យ | ១៦,៩៨ | ៤៣,៤៥ | ១២,៨៣ |
| វិទ្យាល័យ | ១៧,៤៤ | ៤៤,៥៩ | ៣៨,២៩ |
| មធ្យមសិក្សាបឋមភូមិ | ៣២,០៩ | ៤៤,៧៩ | ៥៤,៤៩ |
| មធ្យមសិក្សាទុតិយភូមិ | ១៧,៤៤ | ៤៤,៥៩ | ៣៨,២៩ |

## ការអនុវត្តកម្មវិធីនានា

**កម្មវិធីផ្តល់អាហារូបករណ៍សិស្សក្រីក្រមធ្យមសិក្សា**

កម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅមធ្យមសិក្សាបឋមភូមិ បានគ្រប់ដណ្តប់លើសាលារៀន ៣២ ដែលមានសិស្សអាហារូបករណ៍២៨៨០ នាក់ ក្នុងនោះស្រី១៧២៨ នាក់ និងកម្មវិធីសិស្សអាហារូបករណ៍នៅមធ្យមសិក្សាទុតិយភូមិ បានគ្រប់ដណ្តប់លើសាលារៀនចំនួន ០៦ ដែលមានសិស្សអាហារូបករណ៍ចំនួន៣៦០ នាក់ ក្នុងនោះស្រី២១៦ នាក់ (គាំទ្រដោយថវិកាPB ក្រសួងអប់រំ យុវជន និងកីឡា) ។

**ការអនុវត្តកម្មវិធីទប់ស្កាត់សិស្សបោះបង់ការសិក្សា**

ខេត្តស្វាយរៀងទទួលបានបន្ទប់កុំព្យូទ័រចំនួន ២១សាលា ពីអង្គការ KAPE បច្ចុប្បន្នបន្តនិរន្តរភាពដោយថវិកា PB របស់ក្រសួងអប់រំ យុវជន និងកីឡា ។

**លទ្ធផលប្រឡងជ្រើសរើសសិស្សពូកែថ្នាក់ខេត្ត**

មន្ទីរអប់រំ យុវជន និងកីឡា បានប្រឡងជ្រើសរើសសិស្សពូកែថ្នាក់ខេត្តផ្នែក អក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា ថ្នាក់ទី ៩ និងថ្នាក់ទី ១២ ជាប់ចំនួន១៨ នាក់ ស្រី០៨ នាក់។ បានទៅចូលរួមប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស នៅខេត្តបាត់ដំបង ប៉ុន្តែមិនទទួលបានលទ្ធផលទេ ។

**ការអភិវឌ្ឍន៍ និងអនុវត្តកម្មវិធីសិក្សា**

- លោកគ្រូ អ្នកគ្រូ បានធ្វើកម្មវិធីលម្អិតប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំឆ្នាំ
- លោកគ្រូ អ្នកគ្រូបានបង្រៀនចប់តាមកម្មវិធីរបស់ក្រសួងដែលបានដាក់ឱ្យអនុវត្ត ។

**ការផ្គត់ផ្គង់សៀវភៅសិក្សាគោល**

- សិស្សមធ្យមសិក្សាបឋមភូមិ ផលធៀបសៀវភៅ ០១/០១
- សិស្សទុតិយភូមិផលធៀបសៀវភៅ ០២/០១។

សាលាមួយចំនួនខ្វះសៀវភៅសិក្សាគោលព្រោះ ការធ្វើផែនការតម្រូវការសៀវភៅមិនបានច្បាស់លាស់។

ការងារបណ្ណាល័យ

សាលាចំនួន ០៥ កន្លែង មានបណ្ណាល័យដាច់ដោយឡែក និងសាលាចំនួន ៦៨ កន្លែង យកបន្ទប់រៀន ធ្វើជាបណ្ណាល័យ និងខ្វះសៀវភៅ ឯកសារស្រាវជ្រាវផ្សេងៗ ដូចនេះ ការចូលអានរបស់សិស្សានុសិស្សមានការលំបាក ។

**ខ- ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់**

- ការពង្រឹងប្រព័ន្ធអប់រំ និងពិនិត្យតាមដានផ្អែកលើលទ្ធផលមន្ទីរអប់រំ យុវជន និងកីឡាបាន៖
- បានចុះពិនិត្យ ការប្រឡងឆមាសទាំងពីរលើកពីថ្នាក់ទី ៧ដល់ថ្នាក់ទី ១២ ចំនួន ៧៣សាលា
- បានចុះពិនិត្យតាមដានអាហារូបករណ៍សិស្សក្រីក្រចំនួន ៣២សាលា
- បានចុះពិនិត្យការបង្រៀន និងរៀនចំនួន ២៧សាលា

**គ- ការជួយខួបត្ថម្ភគាំទ្រពីរដ្ឋាភិបាល និងអង្គការដៃគូនានា**

## ការចូលរួមអភិវឌ្ឍពីសំណាក់រដ្ឋាភិបាល អង្គការដៃគូ និងសប្បុរសជន

- អង្គការភីសខ័រកម្ពុជា បានបញ្ជូនអ្នកស្ម័គ្រចិត្តជនជាតិអាមេរិក០៤ នាក់ មកជួយបង្រៀនភាសាអង់គ្លេសនៅវិទ្យាល័យ ហ៊ុនសែន ប្រសូតិ,វិ. ហាស ក្រោលគោ និងវិ.ហាស ជ្រៃធំ និងវិ.ហាស សាមគ្គីជូនស ។
- វិទ្យាល័យ ហ៊ុនសែន សាមគ្គីជូនស៖ បានសាងសង់អគារសិក្សា ០១ខ្នង ០២ជាន់ មាន១២បន្ទប់(ថវិកាក្រសួងអយក)
- វិ.ហាស ប្រសូតិ៖ បានធ្វើខ្លោងទ្វារថ្មី អស់ទឹកប្រាក់ ៣៥,០០០ ដុល្លារ (ថវិកាសប្បុរសជន)
- វិ.ពោធិ៍ធំ៖បានធ្វើបង្គន់អនាម័យ ០១ខ្នង មាន០៣បន្ទប់ អស់ទឹកប្រាក់១,៨៥០,០០០៛(ថវិកាPB)
- អនុវិ. អំពិលពោធិ៍ធំ ៖ បានចាក់ដី២០០ រថយន្ត អស់ទឹកប្រាក់ ៤,០០០,០០០ ៛ និងធ្វើរបង១១ប្លង់ ប្រវែង ៥០ ម៉ែត្រ អស់ទឹកប្រាក់ ២,១៣០,០០០ ៛ (ថវិកាសហគមន៍ និងសប្បុរសជន)
- អនុវិ.សំបួរ៖ បានសាងសង់ទីចាត់ការ ០១ខ្នង ០៣បន្ទប់អស់ទឹកប្រាក់ ៤១,០០០,០០០ ៛(ថវិកា PB +SIG និងសប្បុរសជន)
- អនុវិ.ខ្សែត្រ៖ បានសង់បណ្ណាល័យ ០១ខ្នង ០១បន្ទប់ អស់ទឹកប្រាក់ ២៥,០០០,០០០ ៛(ថវិកាសប្បុរសជន)
- អនុវិ.ច្រេស៖ បានសាងសង់អគារសិក្សា ០១ខ្នង ០៦បន្ទប់ អស់ថវិកា ៣៧៨,៦២២,៤១៤ ៛ (ថវិកាក្រសួងអយក)
- វិ.ស្វាយរៀង៖ កំពុងសាងសង់អគារសិក្សា ០១ខ្នង ០៤ជាន់ មាន៤០បន្ទប់ និងទីចាត់ការ ០១ខ្នង (ថវិកា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន )
- វិ.ហាស សាមគ្គីជូនស៖ បានជួសជុលអគារសិក្សា ០៣ខ្នង មាន១៥បន្ទប់ អស់ទឹកប្រាក់ ២,០០៦,០០០ ៛ (ថវិកាPB និងសប្បុរសជន)
- វិ.ហាស កំពង់ពោធិ៍៖ បានជួសជុលអគារ ០១ខ្នង ០៤បន្ទប់ និងពង្រីក ០១បន្ទប់អស់ថវិកា ៣៦,៥៤៣,០០០ ៛ (ថវិកាសប្បុរសជន និងសហគមន៍)

- វិ.បច្ចេកទេស និងចំណេះទូទៅ បារិតះ បានជួសជុលអគារសិក្សា០២ បន្ទប់ អស់ទឹកប្រាក់ ៨៥៥ ដុល្លារ (ថវិកាសប្បុរសជន )។

**ឃ- វឌ្ឍនភាពនៃសូចនាករផលសម្រេច**

**ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច**

| ល.រ | ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស | ជាក់ស្តែង ២០១៦-១៧ | ចំណុចដៅ ២០១៧-១៨ | ជាក់ស្តែង ២០១៧-១៨ | ស្ថានភាព |
|---|---|---|---|---|---|
| ១ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | 66.08% | 76.86% | 69.00% | ↑ |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ (ស្រី) | 66.94% | 67.86% | 71.70% | |
| ២ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | 27.17% | 25.90% | 29.22% | |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ (ស្រី) | 26.51 | 29.90% | 29% | |
| ៣ | អត្រាឆ្លងភូមិសិក្សាពីម.បឋមភូមិទៅម.ទុតិយភូមិ | 73.80% | 74.50% | 74% | |
| | អត្រាឆ្លងភូមិសិក្សាពីម.បឋមភូមិទៅម.ទុតិយភូមិ (ស្រី) | 76.20% | 76% | 76.80% | |
| ៤ | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | 53.30% | 47.20% | 53.30% | |
| | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ (ស្រី) | 56.56% | 53.69% | 56.30% | |
| ៥ | អត្រាបោះបង់ការសិក្សាបឋមភូមិនៅម.បឋមភូមិ | 16.60% | 13.80% | 16.60% | |
| | អត្រាបោះបង់ការសិក្សាបឋមភូមិនៅម.បឋមភូមិ (ស្រី) | 15.40% | 12.40% | 15.50% | |
| ៦ | ចំនួនសិស្សមធ្យមសិក្សាទទួលអាហារូបករណ៍ | 3,060 នាក់ | 3.240 នាក់ | 3.240 នាក់ | |
| ៧ | ភាគរយគ្រឹះស្ថានមធ្យមសិក្សាអនុវត្តកម្មវិធីសាលាកុមារមេត្រី | 67% | 68% | | |
| ៨ | ភាគរយសាលាមធ្យមសិក្សាមានបង្គន់អនាម័យ | | | | |
| | មធ្យមសិក្សាបឋមភូមិ | 96% | 97% | 100% | |
| | មធ្យមសិក្សាទុតិយភូមិ | 100% | 100% | 100% | |

| | | | | | |
|---|---|---|---|---|---|
| ៩ | ភាគរយសាលាមធ្យមសិក្សាស្អាត | | | | |
| | មធ្យមសិក្សាបឋមភូមិ | | 30% | | |
| | មធ្យមសិក្សាទុតិយភូមិ | | | | |
| ១០ | ចំនួនវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស | 1 | 1 | 1 | |
| ១១ | ចំនួនសិស្សក្នុងការអប់រំបច្ចេកទេស | 0 | 222 នាក់ | 50 នាក់ | |
| | ចំនួនសិស្សក្នុងការអប់រំបច្ចេកទេសស្រី | 0 | 75 | 14 | |
| ១២ | ចំនួនស្រុកដែលសម្រេចបានអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ យ៉ាងតិច ៨០ ភាគរយ | 7/8 | 7/8 | 8/8 | |

សម្គាល់៖ ↑សម្រេចបានតាមចំណុចដៅ ➔អាចទទួលយកបាន ↓សម្រេចមិនបានតាមចំណុចដៅ

ង.បញ្ហាប្រឈម៖

- ខ្វះគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ និងមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជាឯកទេសមួយចំនួននៅតាមវិទ្យាល័យ និងអនុវិទ្យាល័យ
- ខ្វះផ្ទះស្នាក់នៅរបស់គ្រូ តាមវិទ្យាល័យមួយចំនួន
- អត្រាបោះបង់ការសិក្សារបស់សិស្សនៅតែខ្ពស់
- អនុវិទ្យាល័យចំនួន ០៥កន្លែង និងវិទ្យាល័យចំនួន ០៦កន្លែង នៅខ្វះអគារសិក្សា
-ខ្វះគ្រូឯកទេសមុខវិជ្ជាបំណិនជីវិត សម្ភារ និងបន្ទប់រៀន
-ខ្វះបន្ទប់ និងសម្ភារៈពិសោធន៍តាមអនុវិទ្យាល័យ និងវិទ្យាល័យ។

## ២.៤.អនុវិស័យការអប់រំក្រៅប្រព័ន្ធ

**ក.ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា**

**-កម្មវិធីអក្ខរកម្ម៖** មាន៨៥ ថ្នាក់ គ្រូបង្រៀន៨៥ នាក់ ស្រី១៧ នាក់ (គ្រូកិច្ចសន្យា) សិស្សចូលរៀនសរុប៨៤០ នាក់ ស្រី៥៦៣ នាក់ បញ្ចប់ថ្នាក់អក្ខរកម្ម៧៦៨ នាក់ ស្រី៦២២ នាក់។

**-ការងារក្រោយអក្ខរកម្ម៖** បណ្ណាល័យ០២កន្លែង មានអ្នកចូលអានចំនួន ៩៧១ នាក់ ស្រី៥៥៥ នាក់។

**-កម្មវិធីបង្កើនប្រាក់ចំណូល៖** មាន ២០ មជ្ឈមណ្ឌលសិក្សាសហគមន៍ ថ្នាក់ចំនួន៤៦ ថ្នាក់ គ្រូ៤៦ នាក់ ស្រី ២៦ នាក់ (គ្រូកិច្ចសន្យា) មានសិស្សចូលរៀនសរុប ៨២៧ នាក់ ស្រី៥៥៧ នាក់ សិស្សរៀនចប់ចំនួន៥៨៤ នាក់ ស្រី៤១៩ នាក់ បណ្តុះបណ្តាលលើមុខជំនាញ០៦ (កាត់ដេរ សម្អាងការ ភ្លេងប្រពៃណី ជួសជុលម៉ូតូ កសិកម្ម និងពេទ្យសត្វ)។

**-កម្មវិធីចូលរៀនឡើងវិញ៖** មាន៣៥ ថ្នាក់ គ្រូ៣៥ នាក់ ស្រី០៦ នាក់ មានសិស្សសរុប ៦២៩ នាក់ ស្រី ២៩៧ នាក់ សិស្សបានរៀនចប់ចំនួន៦១៥ នាក់ ស្រី២៩៥ នាក់ ។

**-កម្មវិធីសមមូល៖** មានថ្នាក់សមមូលបឋមសិក្សា០៧ ថ្នាក់ គ្រូ០៧ នាក់ ស្រី០០ នាក់ (គ្រូកិច្ចសន្យា ) សិស្ស សរុប ១០៧នាក់ ស្រី ៤៩ នាក់ សិស្សរៀនចប់ ៩៩ នាក់ ស្រី៤៨ នាក់។

**-កម្មវិធីបំពេញវិជ្ជា៖** មធ្យមសិក្សាទុតិយភូមិមាន០២ ថ្នាក់ (ថ្នាក់ទី១២ ក្រៅម៉ោងរៀនថ្ងៃសៅរ៍ និង អាទិត្យ) មានសិស្សចូលរៀន១៣៨ នាក់ ស្រី៣៤ នាក់ បានប្រឡងជាប់៧៤ នាក់ ស្រី១៩ នាក់។

**ការប្រែប្រួលថ្នាក់រៀននៃអប់រំក្រៅប្រព័ន្ធឆ្នាំសិក្សា២០១៥-២០១៦ ប្រៀបធៀបនឹងឆ្នាំសិក្សា ២០១៦-២០១៧**

| បរិយាយ | ឆ្នាំសិក្សា ២០១៥-២០១៦ | ឆ្នាំសិក្សា ២០១៦-២០១៧ | កើន(+)/ថយ(-) | ភាគរយ |
|---|---|---|---|---|
| ថ្នាក់រៀនអក្ខរកម្ម | ៤៥ | ៤៥ | ថេរ | ០០ |
| បណ្ណាល័យ | ០២ | ០២ | ថេរ | ០០ |
| ថ្នាក់ចូលរៀនឡើងវិញ | ៣៥ | ៣៥ | ថេរ | ០០ |
| មជ្ឈមណ្ឌលសិក្សាសហគមន៍ | ២០ | ២០ | ថេរ | ០០ |
| ថ្នាក់ជំនាញមុខរបរ | ៤៦ | ៤៦ | ថេរ | ០០ |
| ថ្នាក់សមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ | ០៨ | ០៧ | -០១ | -១២.៥ |
| ថ្នាក់បំពេញវិជ្ជាមធ្យមសិក្សាបឋមភូមិ | ០១ | ០០ | -០១ | -១០០ |
| ថ្នាក់បំពេញវិជ្ជាមធ្យមសិក្សាទុតិយភូមិ | ០២ | ០២ | ថេរ | ០០ |

**ការប្រែប្រួលសិស្សនៃកម្មវិធីអប់រំក្រៅប្រព័ន្ធឆ្នាំសិក្សា២០១៥-២០១៦ ប្រៀបធៀបនឹងឆ្នាំសិក្សា ២០១៦-២០១៧**

| បរិយាយ | ឆ្នាំសិក្សា ២០១៥-១៦ | | ឆ្នាំសិក្សា ២០១៦-១៧ | | កើន(+)/ថយ(-) | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| គ្រូអក្ខរកម្ម | ៤៥ | ១០ | ៤៥ | ១៧ | ថេរ | +៧ |
| អ្នកសិក្សាកម្មវិធីអក្ខរកម្ម | ៨៦០ | ៦៩០ | ៨៦០ | ៦៩១ | ថេរ | +១ |
| អ្នកសិក្សាជំនាញមុខរបរ | ៦៧៤ | ៤៦១ | ៨២៧ | ៥៥៧ | +១៥៣ | +៩៦ |
| សិស្សសមមូលបឋមសិក្សាអកប | ១២៣ | ៥៩ | ១០៧ | ៤៩ | -១៦ | -១០ |
| សិស្សកម្មវិធីចូលរៀនឡើងវិញ | ៦០៩ | ២៩៧ | ៦២៩ | ២៩៧ | +២០ | ថេរ |

| | | | | | | |
|---|---|---|---|---|---|---|
| សិស្សបំ.វិ.មធ្យមសិក្សាបឋមភូមិ | ១០ | ០០ | ០០ | ០០ | -១០ | ០ |
| សិស្សបំ.វិ.មធ្យមសិក្សាទុតិយភូមិ | ១២៣ | ៣៦ | ១៣៨ | ៣៤ | +១៥ | -២ |




**ខ.ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់**

អនុវិស័យអប់រំក្រៅប្រព័ន្ធបានចូលរួមយ៉ាងសកម្មក្នុងការបណ្តុះបណ្តាលជំនាញនៅមូលដ្ឋាន ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ការធ្វើចំណាកស្រុក និងសិស្សបោះបង់ការសិក្សា ដូចនេះមន្ត្រីនិងគ្រូកិច្ចសន្យាទាមទាសមត្ថភាព គុណភាព និងប្រសិទ្ធភាព ដើម្បីផ្ទេរចំណេះដឹងដល់អ្នកសិក្សា ដោយឆ្លងកាត់វគ្គបំប៉នដូចខាងក្រោម៖

-ប្រធានការិយាល័យអប់រំក្រៅប្រព័ន្ធ០១ នាក់ និងអនុប្រធានមន្ទីរ០១នាក់បានចូលរួមប្រជុំស្តីពីការពិគ្រោះយោបល់លើគ្រូអក្ខរកម្មជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធតាមពេងចក្រនៅខេត្តកំពង់ចាមរយៈពេល០១ថ្ងៃ

-ប្រធានការិយាល័យអប់រំក្រៅប្រព័ន្ធ០១ នាក់ និងមន្ត្រីអយកក្រុងស្រុក០៧នាក់បានចូលរួមសិក្ខាសាលាស្តីពីការលើកកម្ពស់សមត្ថភាពគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍នៅខេត្តកំពង់ស្ពឺរយៈពេល០៣ថ្ងៃ

-អនុប្រធានមន្ទីរ០១ នាក់ ប្រធានការិយាល័យ០១ នាក់ និងមន្ត្រីការិយាល័យអកប០២ នាក់ បានចូលរួមសិក្ខាសាលាស្តីពីការលើកកម្ពស់ការគ្រប់គ្រងកម្មវិធីអក្ខរកម្មនៅខេត្តំពតរយៈពេល០៣ថ្ងៃ

-អនុប្រធានមន្ទីរ០១ នាក់ ប្រធានការិយាល័យអកប០១ នាក់ មន្ត្រីការិយាល័យអកប០២ នាក់ និងមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាស្រុក០១ នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូឧទ្ទេសសម្រាប់កម្មវិធីចូលរៀនឡើងវិញរយៈពេល០៣ ថ្ងៃ នៅខេត្តក្រចេះ

-បានសហការជាមួយអង្គការវ៉ាវប្រារព្ធទិវាអក្ខរកម្ម ៨ កញ្ញា នៅសង្កាត់ស្វាយតឿ ក្រុងស្វាយរៀង មានអ្នកចូលរួម ១០០ នាក់ ស្រី ៣៥ នាក់។

គ.វឌ្ឍនភាពនៃសូចនាករផលសម្រេច

| លរ | ការងារអប់រំក្រៅប្រព័ន្ធ | ជាក់ស្តែង 2015-16 | ចំណុចដៅ 2016-17 | ជាក់ស្តែង 2016-17 | ស្ថានភាព |
|---|---|---|---|---|---|
| **គោលនយោបាយទី១៖** ធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ និងបរិយាប័ន្ននិងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | |
| 1 | ចំនួនប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម | ៧៦៨ | ៨៤០ | ៧៦៨ | ↓ |
| 2 | ចំនួនសិស្សចូលរៀនក្នុងកម្មវិធីសមមូល | ១០៧ | ៩៥ | ៩៩ | ↑ |
| 3 | ចំនួនមជ្ឈមណ្ឌលសិក្សាសហគមន៍ | ២០ | ២០ | ២០ | ↑ |
| 4 | ភាគរយកុមារដែលបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញ និងបានបញ្ជូនទៅក្នុងប្រព័ន្ធ | ៩៧.៧៧ | ៩៨.៥០ | ៩៧.៧៧ | → |
| 5 | ចំនួនអ្នកសិក្សាបានបញ្ចប់វគ្គបណ្តុះបណ្តាលមុខជំនាញ | ៥៨៤ | ៨៤០ | ៥៨៤ | ↓ |
| **គោលនយោបាយទី២៖** ធានាតាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | |
| 6 | រៀបចំប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ | | | | |

សម្គាល់៖ ↑សម្រេចបានតាមចំណុចដៅ →អាចទទួលយកបាន ↓សម្រេចមិនបានតាមចំណុចដៅ

ឃ.បញ្ហាប្រឈម ៖

-ថវិកាទម្លាក់មិនទាន់សកម្មភាពការងារ (កម្មវិធីបង្កើនប្រាក់ចំណូល)

-ការប្រមូលសិស្សបោះបង់ការសិក្សា ឲ្យចូលរៀនឡើងវិញក្នុងកម្មវិធីចូលរៀនឡើងវិញ និង កម្មវិធីសមមូលជួបការលំបាក

-សិស្សដែលបានបណ្តុះបណ្តាលមុខជំនាញរួចហើយមួយចំនួនធំពុំមានលទ្ធភាពយកជំនាញនេះ ទៅប្រកបមុខរបរបានដោយខ្វះប្រភពទុន។

## ២.៥.អនុវិស័យការអភិវឌ្ឍយុវជន

ក.ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

- បានរៀបចំក្រុមប្រឹក្សាយុវជនបាន ១៩ ក្រុម មាន ២៥៨ សាខា កើន ១០ សាខា ស្មើនឹង ១,៥៤៨ អនុសាខាកើន៦០ អនុសាខា មានសមាជិកសរុប១១,១១២ នាក់ កើន៧៩៨ នាក់ ស្រី៥,១៩៨ នាក់ កើន៥៥៦ នាក់ ។

- បានរៀបចំក្រុមប្រឹក្សាកុមារបាន ៣០៩ ក្រុម មាន១,៦១២ សាខា ស្មើនឹង ៩,៦៧២ អនុសាខា មានសមាជិកសរុប ៥៧,៨៧១ នាក់ ស្រី ២៨,៦៥១ នាក់ បើធៀបនឹងឆ្នាំសិក្សា២០១៥-២០១៦ ចំនួនក្រុមប្រឹក្សាថេរ គណៈកម្មាធិការសាខា កើន៤០ អនុសាខា កើន២៤០ សមាជិក កើន ១២៧៧ នាក់ ស្រី៨៨៣ នាក់។
- កាយរឹទ្ធិជាតិកម្ពុជាទូទាំងខេត្តមានៈ
- កាយរឹទ្ធិមានសមាជិកចំនួន ៦,៨១១នាក់ ស្រី ៣,០៩១នាក់
- កាយរឹទ្ធិប្អូនមានសមាជិកចំនួន ៨៤១នាក់ ស្រី ៤៥៤ នាក់
- សមាជិកកាកបាទក្រហមចំនួន ២៥០នាក់ ស្រី ១២៣ នាក់

**ការប្រែប្រួលក្រុមប្រឹក្សាយុវជន កុមារ កាកបាទក្រហម និងកាយរឹទ្ធិ ឆ្នាំសិក្សា ២០១៦-២០១៧ ធៀបនឹងឆ្នាំសិក្សា ២០១៥-២០១៦**

| បរិយាយ | ឆ្នាំសិក្សា | | ស្ថានភាព |
|---|---|---|---|
| | ២០១៥-២០១៦ | ២០១៦-២០១៧ | |
| **ផ្នែកក្រុមប្រឹក្សាកុមារ និងយុវជន** | | | |
| ក្រុមប្រឹក្សាយុវជន | 10,314 នាក់ | 11,112 នាក់ | កើន |
| ក្រុមប្រឹក្សាកុមារ | 56,594 នាក់ | 57,871 នាក់ | កើន |
| សិស្សថ្នាក់ទី៤-៩ ចូលក្នុងក្រុមប្រឹក្សាកុមារ | 308 ក្រុម | 309 ក្រុម | កើន |
| សិស្សថ្នាក់ទី១០-១២ ចូលក្នុងក្រុមប្រឹក្សាយុវជន | 19 ក្រុម | 19 ក្រុម | ថេរ |
| ក្រុមប្រឹក្សា.កុមារដំណើរការប្រកបដោយគុណភាព | 202 សាលា | 204 សាលា | កើន |
| ក្រុមប្រឹក្សាយុវជនដំណើរការប្រកបដោយគុណភាព | 16 សាលា | 17 សាលា | កើន |
| **កាយរឹទ្ធិជាតិកម្ពុជា និងកាកបាទក្រហម** | | | |
| សមាជិកកាយរឹទ្ធិប្អូន | 406 នាក់ | 841 នាក់ | កើន |
| សមាជិកកាយរឹទ្ធិ | 4,563 នាក់ | 6,755 នាក់ | កើន |
| សមាជិកកាកបាទក្រហមនៅតាមវិទ្យាល័យ | 250 នាក់ | 250 នាក់ | ថេរ |




**ខ.ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រង របស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់**

- បានដឹកនាំលំហែ និងទស្សនកិច្ចសិក្សាយុវជន និងកុមារ ទៅខេត្តសៀមរាប ខេត្តរតនៈគីរី ខេត្តកោះកុង បានចំនួន ០៦លើក (ថ្នាក់ខេត្ត ០២ លើក និងថ្នាក់ជាតិ ០៤ លើក) មានអ្នកចូលរួម ១៩២ នាក់ ស្រី ៩០ នាក់ ។
- បានបើកវគ្គសិក្ខាសាលាស្តីពី យុវជនស្ម័គ្រចិត្តថ្នាក់ក្រុង/ស្រុកបានចំនួន០២ វគ្គ មានសិក្ខាកាមសរុប ៥០នាក់ ស្រី ០៤នាក់ នៅស្រុកចន្ទ្រា និងក្រុងបាវិត។
- បានបើកវគ្គសិក្ខាសាលាស្តីពី ការយល់ដឹងពីជំងឺអេដស៍ដល់យុវជនក្រៅសាលាថ្នាក់ឃុំ/សង្កាត់ បានចំនួន០៣ វគ្គ មានសិក្ខាកាមសរុប១៦៥ នាក់ ស្រី៨៥ នាក់ នៅឃុំគគីរសោម ឃុំពងទឹក និងឃុំគោគព្រីង។
- បានបើកវគ្គបំប៉នការពង្រឹងក្រុមប្រឹក្សាយុវជននិងកុមារ ០៣ វគ្គ សិក្ខាកាមចូលរួមសរុប១២៣ នាក់ ស្រី១៤ នាក់ នៅស្រុកស្វាយទាប ស្រុករំដួល និងស្រុកស្វាយជ្រំ។
- ចុះពិនិត្យតាមដាននិងវាយតម្លៃសកម្មភាពការងារក្រុមប្រឹក្សាយុវជន និងកុមារតាមក្រុង/ស្រុក បាន ១០៤សាលា។
- ចុះពិនិត្យតាមដាន និងវាយតម្លៃសកម្មភាពការងារយុវជនស្ម័គ្រចិត្តតាមឃុំ/សង្កាត់បាន ១៩ ឃុំ/សង្កាត់ ។
- បានរៀបចំក្លឹបសកម្មភាពបានចំនួន២២ ក្លឹប ។
- បានរៀបចំប្រារព្ធទិវាយុវជនអន្តរជាតិ១២សីហា នៅសាលមហោស្រពខេត្តស្វាយរៀង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ម៉ែន វិបុល** អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀងមានអ្នកចូលរួមចំនួន៣០០នាក់ ស្រី១៥០ នាក់។

- បានរៀបចំប្រារព្ធទិវាកុមារអន្តរជាតិ១ មិថុនា ២០១៧ នៅសាលប្រជុំឆ្នេរទន្លេ ក្រោមអធិបតីភាព លោកជំទាវ **ពៅ សុភាព** អភិបាលរងខេត្តស្វាយរៀង មានអ្នកចូលរួមចំនួន ៤០០ នាក់ ស្រី ២០០ នាក់ ។

គ.វឌ្ឍនាពនៃសូចនាករផលសម្រេចតាមអនុវិស័យ

| ល.រ | ការអភិវឌ្ឍយុវជន | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ស្ថានភាព |
|---|---|---|---|---|---|
| | | 2016-17 | 2017-18 | 2017-18 | |
| **គោលនយោបាយទី១៖** ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | |
| 1 | ចំនួនយុវជនដែលទទួលបានការបណ្តុះបណ្តាលជំនាញខ្លីៗ | 0 | 40 នាក់ | 40 នាក់ | ↑ |
| ២ | ចំនួនយុវជនដែលទទួលបានការបណ្តុះបណ្តាលពីការងារស្ម័គ្រចិត្ត | 56 នាក់ | 60 នាក់ | 50 នាក់ | → |
| ៣ | ចំនួនមជ្ឈមណ្ឌលយុវជន | 0 | 01 | | |
| ៤ | ចំនួនយុវជនដែលបានបង្កើតការងារដោយខ្លួនឯងក្នុងមួយមជ្ឈមណ្ឌលក្នុងមួយឆ្នាំ | 0 | 0 | | ↓ |
| ៥ | ភាគរយសិស្សថ្នាក់ទី ៤-៩ ចូលក្នុងក្រុមប្រឹក្សាកុមារ | 70% | 100% | 85% | → |
| ៦ | ភាគរយសិស្សថ្នាក់ទី ១០-១២ចូលក្នុងក្រុមប្រឹក្សាយុវជន | 99,36 % | 100 % | 99,40 % | → |
| ៧ | ចំនួនមន្ត្រីទទួលបន្ទុកក្រុមប្រឹក្សាទទួលបានការបណ្តុះបណ្តាលការងារក្រុមប្រឹក្សាកុមារ និងយុវជន | 149 នាក់ | 96 នាក់ | 123 នាក់ | ↑ |
| **គោលនយោបាយទី២៖** ធានាភាពស័ក្តិសិទ្ធិ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | |
| | N/A | | | | |

សម្គាល់៖ ↑សម្រេចបានតាមចំណុចដៅ →អាចទទួលយកបាន ↓សម្រេចមិនបានតាមចំណុចដៅ

ឃ.បញ្ហាប្រឈម

- ក្រុង ស្រុក និងសាលារៀនមួយចំនួន មានការផ្លាស់ប្តូរមន្ត្រីទទួលបន្ទុកការងារកុមារ យុវជន ដែលនាំឲ្យមានការលំបាកដោយសារការយល់ដឹងអំពីតួនាទីភារកិច្ចក្នុងការទទួលខុសត្រូវនៅមានកម្រិត និងទទួលការងារច្រើនផ្នែក។
- មន្ត្រីទទួលបន្ទុកការងារក្រុមប្រឹក្សាកុមារ និងយុវជន នៅសាលារៀនមួយចំនួនពុំសូវយកចិត្តទុកដាក់ជំរុញ សកម្មភាពការងាររបស់ក្រុមប្រឹក្សា។
- ខ្វះការគាំទ្រ ការលើកទឹកចិត្តនិងសហការចូលរួមអនុវត្តពីអ្នកពាក់ព័ន្ធ។
- នៅតាមសាលារៀនមួយចំនួនខ្វះបន្ទប់សម្រាប់រៀបចំក្លឹបសកម្មភាពកុមារ និងយុវជន។
- ការប្រជុំបូកសរុបវាយតម្លៃចលនាប្រឡងប្រណាំង៣ ល្អ ប្រចាំឆ្នាំនៅក្នុងថ្នាក់ខេត្តក្រុង/ស្រុក និងសាលា រៀនពុំមានថវិកាដំណើរការ។
- ការពង្រឹងនិងពង្រីកសមាជិកកាយរឹទ្ធិនៅតាមសាលារៀនមួយចំនួនមិនយកចិត្តទុកដាក់។
- លំហូរថវិកាកម្មវិធីយឺតយ៉ាវមិនទាន់ពេលវេលា។

## ២.៦.អនុវិស័យការអភិវឌ្ឍអប់រំកាយ និងកីឡា

**ក.ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា**

- បានចូលរួមប្រកួតកីឡាបាល់ទាត់ដណ្តើមពានរង្វាន់សម្តេចអគ្គមហាសេនីតេជោ **ហ៊ុន សែន** និងជម្រើសជើងឯកជាតិលើកទី២ មានកីឡាករចូលរួម៦០ នាក់
- បានចូលរួមការប្រកួតកីឡាប៉េតង់ពានរង្វាន់សម្តេចក្រឡាហោម ស ខេង មួយលើក។
- បានរៀបចំការប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ខេត្តមានកីឡាករចំនួន ១.,០២៣ នាក់ រយៈពេល០៧ ថ្ងៃ។
- បានចូលរួមប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ជាតិនៅមណ្ឌលរាជធានីភ្នំពេញ មានកីឡាករចំនួន៩៦ នាក់ រយៈពេល ១០ ថ្ងៃ។
- បានរៀបចំទិវាអប់រំកាយ និងកីឡា រយៈពេល២ ថ្ងៃ នៅសាលាបឋមសិក្សា ២ធ្នូ និងសាលាបឋមសិក្សាព្រះសីហនុ ក្រុងស្វាយរៀង គឺដែលមានសិស្សចូលរួមចំនួន៥៦២ នាក់ លោក អ្នកគ្រូ ៦០ នាក់។
- បានរៀបចំការប្រកួតកីឡាសិស្សមធ្យមសិក្សាថ្នាក់ខេត្ត មានកីឡាករចូលរួមចំនួន ១,០២៣ នាក់ រយៈពេល ០៧ ថ្ងៃ។
- បានចូលរួមប្រកួតកីឡាសិស្សមធ្យមសិក្សាថ្នាក់ជាតិនៅមណ្ឌលកំពង់ចាម មានកីឡាចូលរួមចំនួន១០០ នាក់ រយៈពេល១០ ថ្ងៃ។
- បានចូលរួមការប្រកួតកីឡាបាល់ទាត់ជម្រើសជើងឯកជាតិលើកទី២ មានកីឡាករចូលរួម៣០ នាក់
- បានចូលរួមការប្រកួតកីឡាបាល់ទាត់នារីជម្រើសជើងឯកជាតិប្រចាំឆ្នាំ២០១៧ មានកីឡាការិនីចំនួន២៥ នាក់។
- បានចូលរួមប្រកួតកីឡាបាល់ទាត់ថ្នាលយុវជនអាយុក្រោម១៤ ឆ្នាំ(U14) ចំនួន០១ ក្រុម មានកីឡាករចំនួន២៥ នាក់។

- បានចូលរួមប្រកួតកីឡាបាល់ទាត់ថ្នាលយុវជនអាយុក្រោម១៦ ឆ្នាំ(U16) ចំនួន០១ ក្រុម មានកីឡាករចំនួន២៥ នាក់។
- បានចូលរួមប្រកួតកីឡាទាញព្រ័ត្រថ្នាក់ជាតិចំនួន០២ លើក
- បានចូលរួមជាគណៈកម្មការបច្ចេកទេសប្រណាំងទូកខេត្តស្វាយរៀងឆ្នាំ២០១៧ នៅទន្លេវៃគោ មានទូកខ្ទាតអន្តរជាតិចំនួន៤២ ទូក និងទូកក្តារបីសន្លឹកចំនួន០៤ ទូក។

លទ្ធផលនៃការប្រៀបធៀបមេដាយដែលទទួលបានឆ្នាំ ២០១៦ និង២០១៧

| បរិយាយ | ២០១៦ | | | ២០១៧ | | |
|---|---|---|---|---|---|---|
| | ចំនួនមេដាយទទួលបាន | | | ចំនួនមេដាយទទួលបាន | | |
| | មាស | ប្រាក់ | សំរឹទ្ធ | មាស | ប្រាក់ | សំរឹទ្ធ |
| កីឡាសិស្សបឋមសិក្សា | | | | | | |
| ថ្នាក់ខេត្ត | 0 | 0 | 0 | 0 | 0 | 0 |
| ថ្នាក់ជាតិ | 0 | 0 | 0 | 0 | 0 | 0 |
| កីឡាសិស្សមធ្យមសិក្សា | | | | | | |
| ថ្នាក់ខេត្ត | 0 | 0 | 0 | 0 | 0 | 0 |
| ថ្នាក់ជាតិ | 1 | 0 | 0 | 1 | 2 | 1 |
| កីឡាមហាជន | | | | | | |
| ថ្នាក់ខេត្ត | 0 | 0 | 0 | 0 | 0 | 0 |
| ថ្នាក់ជាតិ | 2 | 2 | 3 | 2 | 2 | 3 |
| **សរុប៖** | **3** | **2** | **3** | **3** | **4** | **4** |

តារាងប្រៀបធៀបគ្រូកីឡាឆ្នាំសិក្សា២០១៥-២០១៦ និង២០១៦-២០១៧

| បរិយាយ | ឆ្នាំសិក្សា២០១៦-២០១៧ | ឆ្នាំសិក្សា២០១៧-២០១៨ | ស្ថានភាព |
|---|---|---|---|
| គ្រូកីឡាបឋមសិក្សា | 0 | 0 | 0 |
| គ្រូកីឡាបង្រៀននៅអនុវិទ្យាល័យ | 9 | 11 | 2 |
| គ្រូកីឡាបង្រៀននៅវិទ្យាល័យ | 48 | 53 | 5 |
| **សរុប៖** | **57** | **64** | |




**ខ.ធានាភាពស័ក្តិសិទ្ធ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់**

-បានចូលរួមវគ្គអាជ្ញាសរុបចំនួន០៤ លើកមានអ្នកចូលរួម ៣១ នាក់ស្រី ០៧នាក់

-បានចូលរួមសិក្ខាសាលាស្តីពីការងារអប់រំកាយ និងកីឡានៅនាយកដ្ឋានកីឡាសិស្សនិស្សិតចំនួន ០១លើកមានអ្នកចូលរួមចំនួន ០២ នាក់ស្រី ០នាក់

-បានចូលរួមសិក្ខាសាលាស្តីពីការងារអប់រំកាយ និងកីឡាសម្រាប់មន្ត្រីទទួលការងារអប់រំកាយ និងកីឡាចំនួន ០១ លើក(នាយកសាលាអនុវិទ្យាល័យ៣១នាក់ស្រី០២នាក់)នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀងរយៈពេល៣ ថ្ងៃ។

-ចូលរួមវគ្គគ្រប់គ្រងព្រឹត្តការកីឡាបាល់ទាត់ចំនួន ០៣ នាក់ ស្រី ០០ នាក់។

-ចុះតាមក្រុង-ស្រុក និងសាលារៀនដើម្បីពិនិត្យមើលការបង្រៀន នឹងរៀនមុខវិជ្ជាអប់រំកាយ-កីឡា ចំនួន៧៥ លើក ចំនួន២៥ សាលាមានថ្នាក់ចំនួន១០០ គ្រូចំនួន៦៨នាក់ និងសរុបចំនួន២,៥០០ នាក់។

**គ.វឌ្ឍនភាពនៃសូចនាករផលសម្រេចតាមអនុវិស័យ**

| ល.រ | ការអប់រំកាយ និងកីឡា | ជាក់ស្តែង ២០១៥-២០១៦ | ចំណុចដៅ ២០១៦-២០១៧ | ជាក់ស្តែង ២០១៦-២០១៧ | ស្ថាន |
|---|---|---|---|---|---|
| **គោលនយោបាយទី១៖** ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | |
| 1 | ចំនួនគ្រូអប់រំកាយចេញថ្មី | 5 | 5 | 5 | ↑ |
| 2 | ចំនួនទីលានដែលបានកែលម្អ | ***8*** | ***8*** | ***8*** | ↑ |
| | ទីលានបាល់ទាត់ | 2 | 2 | 2 | ↑ |
| | ទីលានបាល់ទះ | 4 | 4 | 4 | ↑ |
| | ទីលានបាល់បោះ | 2 | 2 | 2 | ↑ |

| | | | | | |
|---|---|---|---|---|---|
| 3 | ចំនួនគ្រឹះស្ថានមធ្យមសិក្សាមានទីលាន | ***81*** | ***81*** | ***81*** | 🡹 |
| | ទីលានបាល់ទាត់ | 15 | 15 | 15 | 🡹 |
| | ទីលានបាល់ទះ | 64 | 64 | 64 | 🡹 |
| | ទីលានបាល់បោះ | 2 | 2 | 2 | 🡹 |
| 4 | ចំនួនមេដាយមាសទទួលបានក្នុងការប្រកួត | 2 | 3 | 3 | 🡹 |
| **គោលនយោបាយទី២៖** ធានាភាពស័ក្តិសិទ្ធិ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | |
| | N/A | | | | |

សម្គាល់៖ 🡹សម្រេចបានតាមចំណុចដៅ ➔អាចទទួលយកបាន 🡻សម្រេចមិនបានតាមចំណុចដៅ

ឃ.បញ្ហាប្រឈម

-ខ្វះថវិកាសម្រាប់ជួសជុលទីលានកីឡាតាមគ្រឹះនសិក្សា

-ខ្វះសម្ភារៈកីឡាសម្រាប់ហ្វឹកហាត់ និងប្រកួត

-នៅតាមគ្រឹះស្ថានសិក្សាទាំងបឋម និងមធ្យមសិក្សាខ្វះគ្រូអប់រំកាយ និងកីឡា

-នៅតាមក្រុង-ស្រុកគ្មានថវិកាសម្រាប់រៀបចំប្រកួតកីឡាថ្នាក់ក្រុង-ស្រុក។

## III.អនុសាសន៍ និងទិសដៅ

### ១.អនុសាសន៍

- សុំផ្តល់ប្រាក់ឧបត្ថម្ភគ្រូមត្តេយ្យសហគមន៍ឱ្យបានឯកភាពគ្នាទូទាំងខេត្ត
- ស្នើសុំថវិកាសម្រាប់បណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍ផ្លាស់ប្តូរថ្មី
- សុំប្រអប់សង្គ្រោះបឋមចែកជូនតាមសាលារៀនដែលនៅឆ្ងាយពីមណ្ឌលសុខភាព
- ស្នើសុំគ្រូបង្រៀនកម្រិតឧត្តមដល់សាលាដែលខ្វះគ្រូ
- ស្នើសង់ផ្ទះគ្រូ ឱ្យបានគ្រប់វិទ្យាល័យ
- ស្នើសាងសង់អគារសិក្សាដល់សាលាដែលខ្វះ
- ស្នើសុំជួសជុលអគារដែលចាស់ទ្រុឌទ្រោម
- ស្នើសុំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្តល់កញ្ចប់ថវិកាតាមផែនការដែលបានគ្រោងឡើងសម្រាប់ឆ្នាំបន្ទាប់
- ស្នើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្តល់ថវិកាជុំទី១ ឲ្យបានប្រើប្រាស់នៅក្នុងខែមករារៀងរាល់ឆ្នាំ
- ការងារលទ្ធកម្មសុំឱ្យមានតម្លៃសមស្រប និងគុណភាពជាចម្បង
- សំណូមពរការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក រៀបចំបន្ថែមមន្ត្រីទទួលបន្ទុកគ្រប់គ្រងសម្ភារ និងទ្រព្យសម្បត្តិរដ្ឋ

- សូមផ្ដល់គ្រូកីឡាក្នុងមួយឆ្នាំចំនួន ១០ នាក់ ទើបគ្រប់តម្រូវការ
- សូមក្រសួងអប់រំជួសជុលទីលានកីឡានៅតាមគ្រឹះស្ថានសិក្សា និងក្រុង ស្រុក
- សូមក្រសួងអប់រំជួយផ្ដល់សម្ភារកីឡាតាមសាលាឲ្យបានគ្រប់គ្រាន់
- សូមផ្ដល់មេដាយគ្រឿងឥស្សរិយយសការងារតាមឆ្នាំដែលស្នើឲ្យបានទាន់ពេល
- សូមផ្ដល់ថវិកា (PB) សម្រាប់ដំណើរការិយាល័យរដ្ឋបាល
- ពង្រឹងការអនុវត្តប្រព័ន្ធពិនិត្យតាមដានវាយតម្លៃការងារបង្រៀន និងរៀន ការងារគ្រប់គ្រង និងកែលម្អឱ្យកាន់តែមានប្រសិទ្ធភាព
- សុំបើកវគ្គបំប៉នដល់គ្រូជាប់កិច្ចសន្យាទាំងអស់លើផ្នែក(បច្ចេកទេស និងរដ្ឋបាល)ការរៀន និងបង្រៀន
- សុំបើកវគ្គបំប៉នសមត្ថភាពមន្ត្រីគ្រប់គ្រង ពីថ្នាក់ការិយាល័យអប់រំស្រុក ក្រុង រហូតដល់ថ្នាក់ខេត្ត
- បំប៉នការអនុវត្តតួនាទីកិច្ចរបស់ក្រុមប្រឹក្សាកុមារ និងយុវជន ឱ្យមានប្រសិទ្ធភាព
- ផ្សព្វផ្សាយ និងលើកកម្ពស់ការអនុវត្តចលនាប្រឡងប្រណាំងចលនា ៣ល្អ របស់កុមារ យុវជនប្រចាំឆ្នាំឱ្យបានទូលំទូលាយប្រកបដោយគុណភាព
- សូមផ្ដល់ថវិកាកម្មវិធីដោយឡែកសម្រាប់ការងារកុមារ និងយុវជន ថ្នាក់ការិយាល័យក្រុង ស្រុក និងសាលារៀន។

## ២.ទិសដៅ

### ២.១.ការងារអប់រំកុមារតូច

- បន្តការផ្សព្វផ្សាយដល់សហគមន៍ពីសារៈសំខាន់នៃការអប់រំកុមារតូច
- បញ្ចូលមត្តេយ្យសិក្សាសហគមន៍ទៅជាឧបសម្ព័ន្ធក្នុងសាលាបឋមសិក្សាដែលមានថ្នាក់មត្តេយ្យ
- បន្តពង្រឹងសេវាអប់រំកុមារតូចតាមគ្រប់រូបភាព
- ស្វែងរកដៃគូអភិវឌ្ឍនានាដើម្បីជួយដល់កម្មវិធីអប់រំកុមារតូច
- បន្តពង្រឹងសមត្ថភាពគ្រូសាលាមត្តេយ្យធនធានដែលបានបង្កើតថ្មី
- បន្តចុះពិនិត្យតាមដានវាយតំលៃផ្នែកអប់រំកុមារតូច
- កែលំអថ្នាក់រៀនអោយទៅជាថ្នាក់ស្តង់ដារគុណភាព
- ពង្រឹងសមត្ថភាពបន្ថែមដល់គ្រូមត្តេយ្យសិក្សារដ្ឋ និងសហគមន៍
- បន្តកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីអភិវឌ្ឍអោយបានល្អប្រសើរ
- ពង្រឹងគុណភាពសាលាតាមស្តង់ដារឱ្យបាន ៤៨ %
- អនុវត្តតេស្តស្តង់ដារកុមារអាយុ ៥ឆ្នាំឱ្យបាន ៦២ %។

### ២.២.ការងារអប់រំបឋមសិក្សា

- បន្តអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តិនានារបស់ក្រសួងអប់រំ យុវជន និងកីឡានិងរាជរដ្ឋាភិបាល
- សហការជាមួយដៃគូអភិវឌ្ឍនានាដើម្បីគាំទ្រ និងអភិវឌ្ឍអនុវិស័យបឋមសិក្សា
- ពង្រឹងការចុះពិនិត្យតាមដាន វាយតម្លៃ និងកែលម្អលើការងារគ្រប់គ្រង និងបច្ចេកទេស

- ពង្រឹងសមត្ថភាពដល់អ្នកពាក់ព័ន្ធនានា ពិសេសនាយកនាយកសាលាគ្រូបង្រៀន និងក្រុមពិនិត្យតាមដាន ( DTMT )
- បន្តអនុវត្តកម្មវិធីលើកកម្ពស់សុខភាពសិក្សានៅតាមសាលារៀន
- ជំរុញ និងលើកកម្ពស់ដល់សាលារៀនគំរូ និងកម្រងគំរូដែលមាននៅតាមស្រុក/ក្រុង
- បន្តសហការ និងធ្វើផែនការថវិកាសាលារៀនជំនាន់ថ្មី
- បន្តអនុវត្ត និងបង្កើនចំនួនសាលាកុមារមេត្រីក្នុងកម្រិតអភិវឌ្ឍ ។

## ២.៣.ការងារអប់រំមធ្យមសិក្សា

- ពង្រឹងលើការងារបច្ចេកទេស ការងារគ្រប់គ្រង ការងារបង្រៀន និងរៀន និងបរិស្ថាន
- ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ
- បន្តចុះពិនិត្យការបង្រៀន និងរៀន
- បន្តចុះពិនិត្យអាហារូបករណ៍សិស្សក្រី
- បន្តទំនាក់ទំនង និងសហការល្អជាមួយសប្បុរសជន និងអង្គការដៃគូនានា
- បន្តជំរុញការកសាងអនុវិទ្យាល័យជំនាន់ថ្មី
- បន្តជម្រុញការកសាងវិទ្យាល័យមធ្យមសិក្សាចំណេះទូទៅ និងការអប់រំបច្ចេកទេស។

## ២.៤.ការងារអប់រំក្រៅប្រព័ន្ធ

- ផ្សព្វផ្សាយគោលនយោបាយផ្នែកអប់រំក្រៅប្រព័ន្ធឲ្យកាន់តែទូលំទូលាយដល់មូលដ្ឋាន
- ស្រង់ស្ថិតិប្រជាពលរដ្ឋដែលជាអនក្ខរជនឲ្យបានច្បាស់លាស់ដើម្បីកំណត់គោលដៅសម្រាប់បើកថ្នាក់អក្ខរកម្ម
- ពង្រឹងសកម្មភាពមជ្ឈមណ្ឌលសិក្សាសហគមន៍ បណ្ណាល័យ និងមណ្ឌលអានដែលមានស្រាប់
- បង្កើនអត្រាអក្ខរកម្ម ៣.៩% (អាយុ១៥-៤៥ ឆ្នាំ)
- ចុះពិនិត្យតាមដានគ្រប់សកម្មភាពការងារអប់រំក្រៅប្រព័ន្ធនៅតាមមូលដ្ឋាន។

## ២.៥.ការងារអប់រំយុវជន

- គ្រប់ក្រុង/ស្រុក និងគ្រឹះស្ថានសិក្សាត្រូវរៀបចំផែនការសកម្មភាពប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងឆ្នាំសម្រាប់ដឹកនាំសកម្មភាពក្រុមប្រឹក្សាកុមារ និងយុវជនឱ្យបានសមស្របតាមលក្ខណៈជាក់ស្តែងរបស់អង្គភាព ។
- ពង្រឹងរបៀបរបបការងាររបស់ក្រុមប្រឹក្សាកុមារ និងយុវជនដោយកំណត់ឱ្យច្បាស់លាស់ពីតួនាទីភារកិច្ចរបស់គណៈកម្មាធិការប្រតិបត្តិ គណៈកម្មាធិការសាខា អនុសាខា ទៅតាមលក្ខន្តិកៈរបស់ក្រុមប្រឹក្សាកុមារ និងយុវជន ។
- ជំរុញការរៀបចំឱ្យមានក្លឹបកុមារ និងយុវជន និងចាត់តាំងឱ្យមានសកម្មភាពជាប្រចាំ ។
- ផ្សព្វផ្សាយអំពីសិទ្ធិកុមារ និងសុខភាពយុវវ័យ ។
- ដឹកនាំកុមារ និងយុវជនចូលរួមទស្សនកិច្ចសិក្សាថ្នាក់ជាតិ ថ្នាក់ខេត្ត និងចូលរួមបោះជំរុំថ្នាក់ជាតិ ។
- ប្រជុំបូកសរុបចលនាប្រឡងប្រណាំងបីល្អ ថ្នាក់ខេត្ត និងថ្នាក់ជាតិ ។
- ចាត់ចែងរៀបចំប្រារព្ធទិវាកុមារអន្តរជាតិ១មិថុនា និងទិវាយុវជនអន្តរជាតិ១២សីហា ២០១៧។

- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទទួលបន្ទុក អំពីការងារក្រុមប្រឹក្សាយុវជន និងកុមារ ។
- បើកវគ្គបំប៉នដល់យុវជនក្រៅសាលា អំពីមេរោគអេដស៍ ជំងឺអេដស៍ សម្រាប់អ្នកអប់រំបន្តថ្នាក់ឃុំ/សង្កាត់
- បើកវគ្គបណ្តុះបណ្តាលស្តីពីការងារយុវជនស្ម័គ្រចិត្ត ថ្នាក់ក្រុង/ស្រុក ។
- បើកវគ្គបណ្តុះបណ្តាលជំនាញខ្លីដល់យុវជន (ជំនាញកុំព្យូទ័រ)។
- ជំរុញការរៀបចំ និងពង្រឹងសមាជិកកាយរឹទ្ធិជាតិកម្ពុជា នៅតាមវិទ្យាល័យ អនុវិទ្យាល័យ និងបឋមសិក្សា នានាក្នុងខេត្ត ។
- ចុះពិនិត្យតាមដាន និងជំរុញសកម្មភាពការងារក្រុមប្រឹក្សាកុមារ និងយុវជនតាមសាលារៀននៅក្រុង/ស្រុកទាំង៨ក្នុងខេត្ត ។
- ចុះពិនិត្យតាមដាន និងជំរុញសកម្មភាពការងារយុវជនស្ម័គ្រចិត្តតាមឃុំ/សង្កាត់គោលដៅ ។

## ២.៦.ការងារអប់រំកីឡា

- បន្តការរៀបចំបង្កើតគណៈកម្មការកីឡាសិស្ស និងកីឡាមហាជនគ្រប់ ក្រុង-ស្រុក និងសាលារៀន
- បន្តរៀបចំប្រកួតកីឡាសិស្ស និងកីឡាមហាជនថ្នាក់ក្រុង-ស្រុក និងថ្នាក់ខេត្តរៀងរាល់ឆ្នាំ
- ចូលរួមប្រកួតកីឡាសិស្ស និងកីឡាមហាជនគ្រប់វិញ្ញាសាថ្នាក់ភូមិភាគ និងថ្នាក់ជាតិតាមកម្មវិធីក្រសួងកំណត់
- បន្តរៀបចំទិវាអប់រំកាយ និងកីឡាជារៀងរាល់ឆ្នាំ
- បន្តការជួសជុលទីលានកីឡាតាមគ្រឹះស្ថានសិក្សា និងតាមក្រុង-ស្រុក
- បន្តសហការជាមួយអង្គការដៃគូសម្រាប់អភិវឌ្ឍ
- ចូលរួមគ្រប់សកម្មភាពសង្គមកីឡា ។

## ២.៧.ការងារគណនេយ្យ សម្ភារ និងទ្រព្យសម្បត្តិរដ្ឋ

- ទំនាក់ទំនងល្អជាមួយរតនាគារក្នុងការផ្តល់សាច់ប្រាក់
- ពង្រឹងបន្ថែមការិយាល័យជំនាញ និងការិយាល័យអប់រំក្រុងស្រុក រួសរាន់ក្នុងការផ្តល់របាយការណ៍ទូទាត់មកការិយាល័យគណនេយ្យ
- បើកថវិកាសាលារៀនឲ្យបានទាន់ពេល
- ចុះពិនិត្យតាមដាន ណែនាំពីនីតិវិធីហិរញ្ញវត្ថុក្នុងការគ្រប់គ្រង និងប្រើប្រាស់ថវិកា ។
- ចុះពិនិត្យតាមដាន ណែនាំនីតិវិធីកិច្ចបញ្ជីកាសម្ភារ និងទ្រព្យសម្បត្តិរដ្ឋ តាមការិយាល័យអប់រំស្រុក ក្រុង និងសាលារៀន
- ធ្វើផែនការយុទ្ធសាស្ត្រថវិកា (BSP) ២០១៧-២០១៩។

## ២.៨.ការងារអធិការកិច្ច

-ធ្វើអធិការកិច្ចសាលារៀនតាមកាលកំណត់ចំនួន៧២សាលា

-ពិនិត្យតាមដាន និងវាយតម្លៃសាលារៀនចំនួន១០សាលា

-បូកសរុបការងារអធិការកិច្ច(អ្នកចូលរួមចំនួន១៥០នាក់)

-ពង្រឹងការងារDTMTចំនួន៨ស្រុក/ក្រុង

-ចូលរួមសហការវាយតម្លៃតេស្តថ្នាក់អន្តជាតិ(PISA-D)១០សាលា

-ផ្សព្វផ្សាយលទ្ធផលតេស្ត(អ្នកចូលរួម១៥០នាក់)

-ចូលរួមសហការវាយតម្លៃតេស្តស្តង់ដារថ្នាក់ជាតិ(NA)១០សាលា។

## ២.៩.ការងារបុគ្គលិក

- បន្តដាក់បុគ្គលិកអប់រំត្រូវចូលនិវត្តន៍ចំនួន ៦៧ នាក់
- រៀបចំ និងស្នើសុំតែងតាំងមន្ត្រីគ្រប់គ្រងជំនួសមន្ត្រីចូលនិវត្តន៍
- ធ្វើសំណើសុំប្រើប្រាស់គ្រូជាប់កិច្ចសន្យា ចំនួន ៦៧៩ នាក់ គ្រូបង្រៀនពីរពេលចំនួន ១២២ នាក់ និងគ្រូបង្រៀនថ្នាក់គួបចំនួន ៤៧ នាក់ សម្រាប់សាលាដែលខ្វះគ្រូ
- បន្តអនុវត្តការពង្រាយគ្រូពីសាលារៀនដែលលើសគ្រូទៅសាលារៀនដែលខ្វះគ្រូឱ្យបាន ០៥នាក់
- បន្តអនុវត្តកម្មវិធីការគ្រប់គ្រង និង ពង្រឹងប្រសិទ្ធភាពធនធានមនុស្ស
- បន្តបញ្ចូលទិន្នន័យបុគ្គលិកអប់រំឱ្យទាន់បច្ចុប្បន្នភាព
- តាមដានការប្រើប្រាស់ក្របខ័ណ្ឌបុគ្គលិកអប់រំនៅតាមសាលារៀនឱ្យបានត្រឹមត្រូវតាមតម្រូវការជាក់ស្តែង ។

## ២.១០.ការងារផែនការ និងគ្រប់គ្រងជំនួយ

- ពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ(EMIS)មន្ត្រីថ្នាក់ក្រុង ស្រុក  និងសាលារៀន
- រៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ( AOP ) ឆ្នាំ ២០១៧
- រៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៧-២០១៩
- បន្តទំនាក់ទំនងល្អជាមួយគ្រប់មជ្ឈដ្ឋាន សប្បុរសជន  ស្ថាប័នពាក់ព័ន្ធ  អង្គការដៃគូចូលរួម ជួយអភិវឌ្ឍវិស័យអប់រំ ។

## ២.១១.ការងាររដ្ឋបាល

- បន្តពង្រឹងការគ្រប់គ្រង និងចរាចរលិខិតស្នាមឯកសារគ្រប់ប្រភេទឲ្យកាន់តែល្អ
- បន្តស្នើសុំមេដាយគ្រឿងឥស្សរិយយសការងារជូនបុគ្គលិកអប់រំចំនួន  ៤៧៦  គ្រឿង  សម្រាប់ឆ្នាំ ២០១៨
- បន្តស្នើសុំមេដាយស្ថាបនាជាតិជូនសប្បុរសជនជាតិ និងអន្តរជាតិ
- បន្តធ្វើលិខិតថ្លែងអំណរគុណាជូនសប្បុរសជន
- បន្តពិនិត្យតាមដានការងារគ្រប់គ្រងរដ្ឋបាល និងបណ្ណសារនៅតាមការិយាល័យអប់រំ យុវជន និងកីឡាស្រុក ក្រុង និងសាលារៀន)
- ចូលរួមក្នុងពិធីបុណ្យជាតិ អន្តរជាតិ
- បន្តកែលំអបរិស្ថាន និងអនាម័យក្នុងអង្គភាព
- បន្តការពារសុវត្ថិភាពសណ្តាប់ធ្នាប់ក្នុងអង្គភាពឲ្យបានល្អ។

VI. **សេចក្ដីសន្និដ្ឋាន**

មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង អបអរសាទរ និងសមិទ្ធផលដែលសម្រេចបានក្នុងឆ្នាំសិក្សា២០១៦-២០១៧ ដែលបានឆ្លុះបញ្ចាំងពីវឌ្ឍនភាពកំណែទម្រង់សំខាន់ៗ និងវឌ្ឍនភាពអនុវិស័យទាំង៦ ធៀបនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៥-២០១៧ ផែនការយុទ្ធសាស្ត្រថវិកា និងផែនការប្រតិបត្តិឆ្នាំ២០១៧។ ទោះជាយ៉ាងណាមន្ទីរ នឹងយកចិត្តទុកដាក់រកដំណោះស្រាយបញ្ហាប្រឈមដែលបានលើកឡើងយកមកធ្វើការកែលម្អ កាត់បន្ថយចំណុចខ្វះខាតដែលមាន ហើយលើកទិសដៅការងារអាទិភាពសម្រាប់ឆ្នាំថ្មី និងស្វែងរកដៃគូអភិវឌ្ឍ សប្បុរសជនបន្ថែមទៀត សំដៅឲ្យវិស័យអប់រំខេត្តស្វាយរៀង មានការអភិវឌ្ឍឈានឡើង ទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងកសាងធនធានមនុស្សពេញលេញក្រប ដោយចំណេះដឹង ចំណេះធ្វើ មានសីលធម៌ល្អ និងចេះរស់នៅជាមួយគ្នាដោយសុខដុមរមនាក្នុងសង្គម។

វឌ្ឍនភាពនេះបង្ហាញឲ្យឃើញនូវការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ ចិត្ត ប្រាជ្ញា ស្មារតីរបស់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងបុគ្គលិកអប់រំនៅទូទាំងខេត្តរួមសហការជាមួយសប្បុរសជនគ្រប់ទិសទី និងអង្គការដៃគូអភិវឌ្ឍនានា ក្នុងការបំពេញភារកិច្ចជួយឧបត្ថម្ភគាំទ្រ លើកស្ទួយកិច្ចអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡានៅក្នុងខេត្តស្វាយរៀង៕

# ប្រធានបទពិភាក្សា

## I- អនុវិស័យ ការអប់រំកុមារតូច

**Sub-sector: Early Childhood Education**

1. ការគ្រប់គ្រងតាមសាលារៀន

   School-based management.

2. ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ។

   Community pre-school management.

## II- អនុវិស័យ ការអប់រំបឋមសិក្សា

**Sub-sector: Primary Education**

1. ការគ្រប់គ្រងតាមសាលារៀន។

   School based management.

2. សាលាកុមារមេត្រីក្នុងបរិបទគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤។

   Child Friendly School in SDG4 context.

## III- អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស

**Sub-sector: Secondary and Technical education**

1. ការគ្រប់គ្រងតាមសាលារៀន ។

   School based management .

2. ការរៀបចំស្តង់ដាសាលារៀនមធ្យមចំណេះទូទៅ និងមធ្យមសិក្សាបច្ចេកទេស។

   Preparing standard of general secondary education and technical secondary schools.

3. ការអនុវត្តគោលនយោបាយ STEM។

   Implementation of STEM policy.

## IV- អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ

**Sub-sector: Non-formal Education**

1. ការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធក្នុងក្របខណ្ឌការសិក្សាពេញមួយជីវិត។

   Implementation of non-formal education programs within lifelong learning framework.

2. ការអភិវឌ្ឍកម្មវិធីសិក្សាអក្ខរកម្មឆ្លើយតបនឹងការអប់រំប្រកបដោយចីរភាព។

   Literacy curriculum development responding to sustainable education goals.

## V- អនុវិស័យ ការអភិវឌ្ឍយុវជន

**Sub-sector: Youth Development**

1. ការពង្រីកកម្មវិធីសហគ្រិនភាព សម្រាប់យុវជននៅក្នុងសាលា និងនៅតាមសហគមន៍។

Expanding entrepreneurship program for youth in school and community.

2. ការពង្រឹង និងពង្រីកក្រុមប្រឹក្សាអភិវឌ្ឍន៍កុមារ យុវជន នៅតាមគ្រឹះស្ថានសិក្សា។

   Strengthening and expanding child and youth development councils in school.

3. ពង្រឹង និងពង្រីកមជ្ឈមណ្ឌលយុវជននៅតាមមន្ទីរអប់រំ យុវជន និងកីឡា។

   Strengthening and expanding youth centers in PoE.

## VI- អនុវិស័យ ការអប់រំកាយ និងកីឡា

**Sub-sector: Physical education and Sport**

1. កីឡាជាវិស័យអាទិភាពមួយរបស់ជាតិ។

   Sport is one of the National Priorities.

2. ការបណ្តុះថ្នាលនិស្ស័យកីឡាឆ្ពោះទៅកីឡាស៊ីហ្គេមឆ្នាំ២០២៣។

   Training talent based sport towards the SEA Game 2023 champion.

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ខេត្តស្វាយរៀង**

**មន្ទីរអប់រំ យុវជន និងកីឡា**

# ស្ថិតិអគារដែលបានសាងសង់ឆ្នាំ២០១៧ និងកំពុងសាងសង់ឆ្នាំ២០១៨

| ល.រ | ឈ្មោះសាលា | ប្រភេទអគារ | ចំនួនអគារ | ចំនួនបន្ទប់ | ស្ថានភាពអគារ | | ប្រភព | ក្រុង/ស្រុក | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | | ធ្វើអំពី | សង់ថ្មី/ជួសជុល | | | |
| 1 | អនុវិទ្យាចន្ទ្រា | អគារសិក្សា | 1 | 3 | ថ្ម | សង់ថ្មី | JHP | ចន្ទ្រា | កំពុងសាងសង់ |
| 2 | បឋមវត្តចំបក់ធំ | អគារសិក្សា | 1 | 5 | ថ្ម | សង់ថ្មី | តាប៊ីថា | ចន្ទ្រា | |
| 3 | បឋមសិក្សាត្នោត | អគារសិក្សា | 1 | 2 | ថ្ម | សង់ថ្មី | JHP | កំពង់រោទិ៍ | |
| 4 | បឋមសិក្សាជុបព្រីង | អគារសិក្សា | 1 | 3 | ថ្ម | សង់ថ្មី | CASINO ព្រៃវល្លិ៍ | កំពង់រោទិ៍ | |
| 5 | មត្តេយ្យធនធាន ហស កំពង់រោទិ៍ | អគារធនធាន | 1 | 5 | ថ្ម | សង់ថ្មី | WB | កំពង់រោទិ៍ | |
| 6 | បឋមសិក្សាវត្តញរ | អគារសិក្សា | 1 | 5 | ថ្ម | សង់ថ្មី | សប្បុរសជន | កំពង់រោទិ៍ | |
| 7 | អនុវិទ្យាល័យថ្នាធ្នង់ | អគារសិក្សា | 1 | 5 | ថ្ម | សង់ថ្មី | ក្រសួង.អយក | រំដួល | |
| 8 | អនុវិទ្យាល័យស្វាយចេក | អគារសិក្សា | 1 | 5 | ថ្ម | សង់ថ្មី | WB | រំដួល | កំពុងសាងសង់ |
| 9 | វិទ្យាល័យ ហស កំពង់ចក | អគារសិក្សា | 1 | 10 | ថ្ម | សង់ថ្មី | ក្រសួង.អយក | រំដួល | កំពុងសាងសង់ |
| 10 | មត្តេយ្យធនធាន កំពង់ចក | អគារធនធាន | 1 | 5 | ថ្ម | សង់ថ្មី | WB | រំដួល | |
| 11 | បឋមសិក្សាហស មុខដា | អគារសិក្សា | 1 | 5 | ថ្ម | សង់ថ្មី | ឯ.ឧ សៅ សុខា | រមាសហែក | |
| 12 | បឋមសិក្សា វត្តត្រស់ | អគារសិក្សា | 1 | 5 | ថ្ម | សង់ថ្មី | សម្តេចពញាចក្រី ហេង សំរិន | រមាសហែក | |
| 13 | បឋមសិក្សាតាសួស | អគារសិក្សា | 1 | 2 | ដែក និងស័ង្កសី | សង់ថ្មី | សប្បុរសជន អូស្ត្រាលី | រមាសហែក | |
| 14 | ការិ.អយកស្រុក រមាសហែក | អគាររដ្ឋបាល | 1 | | ថ្ម | សង់ថ្មី | WB | រមាសហែក | |
| 15 | បឋមសិក្សាចារ | អគារសិក្សា | 1 | 6 | ថ្ម | សង់ថ្មី | អង្គការ ឆាយហ្វាន | ស្វាយជ្រំ | |
| 16 | បឋមសិក្សាស្វាយផ្អែម | បណ្ណាល័យ | | 1 | ថ្ម | ជួសជុល | អង្គការ ឆាយហ្វាន | ស្វាយជ្រំ | |
| 17 | បឋមសិក្សាអង្គកប្បាស់ | បណ្ណាល័យ | | 1 | ថ្ម | ជួសជុល | អង្គការ ឆាយហ្វាន | ស្វាយជ្រំ | |
| 18 | បឋមសិក្សាសំរោងពេជ្រ | បណ្ណាល័យ | | 1 | ថ្ម | ជួសជុល | អង្គការ ឆាយហ្វាន | ស្វាយជ្រំ | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 19 | បឋមសិក្សាភូមិថ្មី | អគារសិក្សា | 1 | 4 | ថ្ម | សង់ថ្មី | មូលនិធិឃុំ | ស្វាយជ្រំ | |
| 20 | មណ្ឌលយុវជនធានស្រុកស្វាយជ្រំ | អគារធនធាន | 1 | 5 | ថ្ម | សង់ថ្មី | WB | ស្វាយជ្រំ | |
| 21 | បឋមសិក្សាភូមិធំ | អគារសិក្សា | 1 | 3 | ថ្ម | សង់ថ្មី | សប្បុរសជន | ស្វាយជ្រំ | |
| | បឋមសិក្សាភូមិធំ | បណ្ណាល័យ | 1 | | ថ្ម | សង់ថ្មី | សប្បុរសជន | ស្វាយជ្រំ | |
| 22 | បឋមសិក្សាពន្លាអកនាត | អគារសិក្សា | 1 | 4 | ថ្ម | សង់ថ្មី | សហគមន៍ | ស្វាយរៀង | |
| 23 | បឋមសិក្សាព្រះសីហនុ | អគារសិក្សា | 1 | 20 | ថ្ម | សង់ថ្មី | សម្តេចតេជោ ហ៊ុន សែន | ស្វាយរៀង | កំពុងសាងសង់ |
| 24 | វិទ្យាល័យស្វាយរៀង | អគារសិក្សា | 1 | 40 | ថ្ម | សង់ថ្មី | សម្តេចតេជោ ហ៊ុន សែន | ស្វាយរៀង | កំពុងសាងសង់ |
| | វិទ្យាល័យស្វាយរៀង | ទីចាត់ការ | 1 | 3 | ថ្ម | សង់ថ្មី | សម្តេចតេជោ ហ៊ុន សែន | ស្វាយរៀង | កំពុងសាងសង់ |
| 25 | បឋមសិក្សាអនុវត្ត | អគារសិក្សា | 1 | 12 | ថ្ម | សង់ថ្មី | សម្តេចតេជោ ហ៊ុន សែន | ស្វាយរៀង | កំពុងសាងសង់ |
| | បឋមសិក្សាអនុវត្ត | ទីចាត់ការ | 1 | 3 | ថ្ម | សង់ថ្មី | សម្តេចតេជោ ហ៊ុន សែន | ស្វាយរៀង | កំពុងសាងសង់ |
| 26 | គរុកោសល្យខេត្ត | ទីចាត់ការ | 1 | 3 | ថ្ម | សង់ថ្មី | សម្តេចតេជោ ហ៊ុន សែន | ស្វាយរៀង | កំពុងសាងសង់ |
| | គរុកោសល្យខេត្ត | អគារសិក្សា | 1 | 16 | ថ្ម | សង់ថ្មី | សម្តេចតេជោ ហ៊ុន សែន | ស្វាយរៀង | |
| | គរុកោសល្យខេត្ត | អន្តេវាសិកដ្ឋាន | 1 | 20 | ថ្ម | សង់ថ្មី | សម្តេចតេជោ ហ៊ុន សែន | ស្វាយរៀង | កំពុងសាងសង់ |
| 27 | បឋមសិក្សាឈើទាល | អគារសិក្សា | 1 | 5 | ថ្ម | សង់ថ្មី | សប្បុរសជនជប៉ុន | ស្វាយទាប | |
| 28 | អនុវិទ្យាល័យព្រៃតាអី | អគារសិក្សា | 1 | 5 | ថ្ម | សង់ថ្មី | WB | ស្វាយទាប | |
| | អនុវិទ្យាល័យសំបួរ | ទីចាត់ការ | 1 | 3 | ថ្ម | សង់ថ្មី | PB+ សប្បុរសជន | ស្វាយទាប | |
| | បឋមពោធិ៍ទន្ទឹម | ទីចាត់ការ | 1 | 3 | ថ្ម | សង់ថ្មី | ឯ.ឧ សៅ សុខា | ស្វាយទាប | កំពុងសាងសង់ |
| 29 | បឋមសិក្សាអង្គសាលា | អគារសិក្សា | 1 | 5 | ថ្ម | សង់ថ្មី | WB | បាវិត | |
| 30 | មណ្ឌលយុវជនធានបាវិត | អគារធនធាន | 1 | 5 | ថ្ម | សង់ថ្មី | WB | បាវិត | |
| 31 | ការិ.អយកក្រុងបាវិត | អគាររដ្ឋបាល | 1 | | ថ្ម | សង់ថ្មី | WB | បាវិត | |
| សរុប | | | 35 ខ្នង | 228 បន្ទប់ | | | | | |

ថ្ងៃព្រហស្បតិ៍ ៣រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស២៥៦១

ស្វាយរៀង, ថ្ងៃទី០៤ ខែមករា គ.ស ២០១៧

បានឃើញ និងឯកភាព

ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត

ជ.ប្រធាន

**សរ_ផល្លា**

ប្រធានការិយាល័យផែនការ និងគ្រប់គ្រងជំនួយ

**ជ័ន_សាវ័ន**

Prepared by: Planning and Aid Management office

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តស្វាយរៀង

មន្ទីរអប់រំ យុវជន និងកីឡា

## ស្ថិតិក្របខ័ណ្ឌបុគ្គលិកអប់រំខេត្តស្វាយរៀង ប្រចាំខែ មករា ឆ្នាំ២០១៨

| អង្គភាព | គ្រូបង្រៀនកម្រិតឧត្តម | | | | គ្រូបង្រៀនកម្រិតមូលដ្ឋាន | | | | | | | | គ្រូបង្រៀនកម្រិតបឋម | | | | កម្មករ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំណេះទូទៅ | | គាសារអប់គ្លេស | | ចំណេះទូទៅ | | គាសារអប់គ្លេស | | គាសាបារាំង | | អប់រំកាយ កីឡា | | បឋមសិក្សា | | មត្តេយ្យសិក្សា | | | | | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| មន្ទីរ.អយកខេត្ត | 30 | 4 | 1 | 0 | 48 | 10 | 8 | 0 | 0 | 0 | 4 | 1 | 23 | 4 | 1 | 1 | 0 | 0 | 115 | 20 |
| សាលាគរុកោសល្យ | 23 | 2 | 0 | 0 | 15 | 6 | 2 | 1 | 0 | 0 | 2 | 1 | 13 | 6 | 0 | 0 | 2 | 2 | 57 | 18 |
| វិ.ស្វាយរៀង | 50 | 11 | 3 | 0 | 82 | 38 | 9 | 6 | 7 | 4 | 9 | 0 | 0 | 0 | 0 | 0 | 0 | 0 | 160 | 59 |
| មត្តេយ្យកុមារថ្មី | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 17 | 17 | 2 | 1 | 19 | 18 |
| បំពេញវិជ្ជាខេត្ត | 2 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 2 | 1 |
| ក្រុង ស្វាយរៀង | 16 | 8 | 1 | 0 | 71 | 26 | 5 | 1 | 2 | 0 | 3 | 2 | 214 | 97 | 33 | 33 | 2 | 0 | 347 | 167 |
| ស្រុក ស្វាយជ្រំ | 85 | 32 | 3 | 0 | 405 | 126 | 45 | 14 | 6 | 3 | 16 | 3 | 518 | 200 | 59 | 56 | 2 | 0 | 1139 | 434 |
| ស្រុក ស្វាយទាប | 51 | 12 | 4 | 1 | 184 | 56 | 12 | 2 | 4 | 4 | 7 | 0 | 204 | 69 | 25 | 25 | 0 | 0 | 491 | 169 |
| ស្រុក កំពង់រោទិ៍ | 38 | 8 | 6 | 1 | 223 | 49 | 21 | 8 | 3 | 3 | 24 | 7 | 256 | 81 | 26 | 24 | 1 | 0 | 598 | 181 |
| ស្រុក រំដួល | 75 | 12 | 4 | 0 | 213 | 65 | 36 | 14 | 3 | 2 | 5 | 0 | 262 | 99 | 10 | 9 | 0 | 0 | 608 | 201 |
| ស្រុក ចន្ទ្រា | 9 | 2 | 2 | 0 | 67 | 11 | 7 | 1 | 1 | 0 | 0 | 0 | 101 | 16 | 3 | 3 | 0 | 0 | 190 | 33 |
| ក្រុង បាវិត | 46 | 10 | 4 | 1 | 95 | 12 | 9 | 1 | 2 | 0 | 7 | 0 | 116 | 21 | 4 | 3 | 0 | 0 | 283 | 48 |
| ស្រុក រមាសហែក | 62 | 14 | 5 | 0 | 349 | 78 | 27 | 9 | 14 | 6 | 8 | 1 | 379 | 133 | 13 | 13 | 0 | 0 | 857 | 254 |
| សរុប | 487 | 116 | 33 | 3 | 1752 | 477 | 181 | 57 | 42 | 22 | 85 | 15 | 2086 | 726 | 191 | 184 | 9 | 3 | 4866 | 1603 |
| | 520 | | 119 | | 2060 | | | | 571 | | | | 2286 | | | 913 | | | | |

បានឃើញ និងឯកភាព

ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត,

ខៀវ_សំអុល

ស្វាយរៀង ,ថ្ងៃទី ០៩ ខែមករា ឆ្នាំ២០១៨

ក. ប្រធានការិយាល័យបុគ្គលិក និងបណ្តុះបណ្តាល,

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរអប់រំ យុវជន និងកីឡា**

**ខេត្តស្វាយរៀង**

*របាយការណ៍ចំណូល ចំណាយថវិការដ្ឋតិតតាមជំពូក ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៧*

*( គិតត្រឹមថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ) របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង*

ឯកតា រៀល

| ជំពូក | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ដើមឆ្នាំ | ស្ថានភាព ឥណទានថ្មី | អនុវត្តជាក់ស្តែង | ឥណទាន នៅសល់ | សមាមាត្រ ប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| **I-សរុបចំណាយ** | | **14,000,000** | **14,000,000** | **19,600,000** | **-5,600,000** | **140.00%** | |
| 73 | ផលទុនពីការលក់ ជួល ទ្រព្យសម្បត្តិ និងសេវា | 14,000,000 | 14,000,000 | 17,643,000 | -3,643,000 | 126.02% | បេក្ខជនដាក់ពាក្យប្រឡងគ្រូកើន |
| 76 | ផលហិរញ្ញវត្ថុផ្សេងៗទៀត | - | - | 1,957,000 | -1,957,000 | 0.00% | |
| **II -សរុបចំណាយ** | | 94,971,100,000 | 85,340,400,000 | 81,336,714,377 | 4,003,685,623 | 95.31% | |
| 60 | ការទិញ | 3,789,700,000 | 3,789,700,000 | 3,522,630,950 | 267,069,050 | 92.95% | |
| 61 | សេវាកម្ម | 3,766,500,000 | 3,799,500,000 | 3,662,945,109 | 136,554,891 | 96.41% | |
| 64 | បន្ទុកបុគ្គលិក | 83,831,900,000 | 74,168,200,000 | 70,583,027,818 | 3,585,172,182 | 95.17% | |
| 62 | អត្ថប្រយោជន៍សង្គម | 3,567,000,000 | 3,567,000,000 | 3,566,610,500 | 389,500 | 99.99% | |
| 63 | ពន្ធ និងអាករ | 16,000,000 | 16,000,000 | 1,500,000 | 14,500,000 | 9.38% | |
| 65 | ឧបត្ថម្ភធន និងជំនួយសង្គម | - | - | - | - | 0.0% | |

ស្វាយរៀង.ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ២០១៧

បានឃើញ និងពិនិត្យត្រឹមត្រូវ

អ្នកធ្វើតារាង

បានឃើញ និង ឯកភាព

**ប្រធានការិយាល័យផែនការគណនេយ្យ**

**ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត**

**អនុប្រធាន**

**ឆេត-មុន្នីរ័ត្ន**

ប៉ែន ថៃ

**សរ-ផល្លា**